ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ
លេខ:.................អសជ/.....

# របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការ ស្តីពីការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ នៅខេត្តមណ្ឌលគិរី

ការិយបរិច្ឆេទ ២០២២

អគារលេខ ៥ ផ្លូវឌួងងៀប៣ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
# 5, St. Duong Ngeab 3, Sangkat Tekthla, Khan Sensok, Phnom Penh, CAMBODIA
Tel:(855-23) 885 900, (855-12) 737 622 Fax: (855-023) 885 900
E-mail: naakh@naa.gov.kh website: www.naa.gov.kh

# របាយការណ៍សវនកម្ម
# លើកិច្ចប្រតិបត្តិការស្តីពីការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
# នៅខេត្តមណ្ឌលគិរី សម្រាប់ការិយបរិច្ឆេទ២០២២

## សេចក្តីសង្ខេប

អនុលោមតាមច្បាប់មាត្រា២ មាត្រា៣ និងមាត្រា៩ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ អាជ្ញាធរសវនកម្មជាតិបានជ្រើសរើសប្រធានបទការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅខេត្តមណ្ឌលគិរី ដើម្បីធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ សម្រាប់ការិយបរិច្ឆេទ ២០២២ និងឆ្នាំពាក់ព័ន្ធ ដោយមូលហេតុរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ មិនទាន់បានបញ្ចប់ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពខ្លួនឱ្យបានទាន់ពេលវេលាកំណត់នៅតាមឆ្នាំនីមួយៗឡើយ ហើយម្យ៉ាងវិញទៀត ក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋដែលបានរៀបចំរួចក៏នៅមានខ្វះចន្លោះទិន្នន័យមួយចំនួន ដូចជា ការមិនទាន់បានកត់ត្រាទ្រព្យសម្បត្តិរដ្ឋមួយចំនួនចូលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ការមិនទាន់បានជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋមួយចំនួន ដែលមានស្ថានភាពទ្រុឌទ្រោមប្រើប្រាស់លែងកើត និងការមិនទាន់បានធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ជាដើម។

អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ ស្តីពីការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅខេត្តមណ្ឌលគិរី សម្រាប់ការិយបរិច្ឆេទ២០២២ និងឆ្នាំពាក់ព័ន្ធ ដើម្បីវាយតម្លៃអំពីភាពសន្សំសំចៃ ប្រសិទ្ធភាព និងប្រសិទ្ធផល នៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងរួមចំណែកក្នុងការតាមដានការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មលើកិច្ចប្រតិបត្តិការស្តីពីការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅខេត្តមណ្ឌលគិរី សម្រាប់ការិយបរិច្ឆេទ២០២២ និងឆ្នាំពាក់ព័ន្ធ ដោយផ្តោតសំខាន់លើការអនុវត្តតួនាទី និងភារកិច្ចរបស់រដ្ឋបាលខេត្ត មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ទីរជំនាញពាក់ព័ន្ធ។

តាមរយៈការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការស្តីពីការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ នៅខេត្តមណ្ឌលគិរី សម្រាប់ការិយបរិច្ឆេទ២០២២ និងឆ្នាំពាក់ព័ន្ធ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋបាលខេត្ត និងមន្ទីរជំនាញពាក់ព័ន្ធមួយចំនួន នៅមានចំណុចខ្វះខាតមួយចំនួន ដូចខាងក្រោម៖

១. ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋមានការយឺតយ៉ាវ

២. ការមិនទាន់កត់ត្រា និងជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការមិនទាន់កំណត់អត្តសញ្ញាណទ្រព្យសម្បត្តិរដ្ឋ

៣. ការមិនទាន់បានធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

៤. ការមិនទាន់បានរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាព និងបញ្ហាប្រឈម នៃការរៀបចំ និងការកត់ត្រាបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

ផ្អែកតាមលទ្ធផលដែលបានបរិយាយនៅផ្នែកទី៣ និងផ្នែកទី៤ នៅក្នុងរបាយការណ៍សវនកម្មស្តីពីការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ នៅខេត្តមណ្ឌលគិរី សម្រាប់ការិយបរិច្ឆេទ២០២២ និងឆ្នាំពាក់ព័ន្ធ អាជ្ញាធរសវនកម្មជាតិសូមផ្តល់អនុសាសន៍ ដូចខាងក្រោម៖ ...

៥.១. រដ្ឋបាលខេត្ត គួរជំរុញដល់គណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់រដ្ឋបាលខេត្ត និងក្រុមការងារបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពប្រើប្រាស់ រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ឱ្យបានទាន់ពេលវេលាកំណត់។

៥.២. រដ្ឋបាលខេត្ត គួរជំរុញដល់គណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលខេត្ត កត់ត្រាទ្រព្យសម្បត្តិរដ្ឋចូលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

៥.៣. រដ្ឋបាលខេត្ត គួរណែនាំដល់ក្រុមការងារបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពប្រើប្រាស់ លើកសំណើសុំជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

៥.៤. រដ្ឋបាលខេត្ត គួរណែនាំដល់ក្រុមការងារបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពប្រើប្រាស់ កំណត់អត្តសញ្ញាណទ្រព្យសម្បត្តិរដ្ឋឱ្យបានច្បាស់លាស់។

៥.៥. រដ្ឋបាលខេត្ត គួរណែនាំដល់គណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលខេត្ត និងក្រុមការងារបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់អង្គភាពប្រើប្រាស់ ត្រូវស្នើសុំធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដើម្បីការពារទ្រព្យសម្បត្តិរដ្ឋឱ្យបានគង់វង្ស។

៥.៦. រដ្ឋបាលខេត្ត គួរណែនាំដល់ទីចាត់ការហិរញ្ញវត្ថុរបស់រដ្ឋបាលខេត្ត និងក្រុមការងារបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពប្រើប្រាស់ រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាព និងបញ្ហាប្រឈម នៃការរៀបចំ និងកត់ត្រាបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ជូនគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដើម្បីពិនិត្យ និងដោះស្រាយ។